បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 13 ខែ 06 ឆ្នាំ 2003

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២៩-១១-២០០១ | - ព្រះរាជក្រឹត្យ នស/រកត/១១០១/៤៤៣ ស្ដីពីការដាក់ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌរដ្ឋបាលសាធារណៈមន្ត្រីថ្នាក់ដឹកនាំនិងទីប្រឹក្សាអមក្រសួង និងឧត្ដមក្រុមប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រចំនួន ០៦ រូប | ៣០៧០ |
| ៣០-១១-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/១១០១/៤៤៤ ស្ដីពីការតែងតាំង អ្នកម្នាង **ឈូរី ស៊ីសុវត្ថិ** ជាឧបការីប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា | ៣០៧១ |
| ៣០-១១-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/១១០១/៤៤៥ ស្ដីពីការតែងតាំងលោក ជំទាវ **សាំង សុម៉ាលី** ជាទីប្រឹក្សាប្រធានរដ្ឋសភាបន្ថែមលើមុខងារបច្ចុប្បន្ន | ៣០៧២ |
| ៣០-១១-២០០១ | - ព្រះរាជក្រឹត្យ នស/រកត/១១០១/៤៤៦ ស្ដីពីការតែងតាំងឯក ឧត្ដម **ខៀវ ដារិន** ជាទីប្រឹក្សាប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាទទួលបន្ទុកពាក្យបណ្ដឹងផ្សេងៗ | ៣០៧៣ |
| ៣០-១១-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/១១០១/៤៤៧ ស្ដីពីការតែងតាំង លោកជំទាវ **ឈឹម ណារ៉ា** ឧបការីប្រធានរដ្ឋសភានៃព្រះរាជណាចក្រកម្ពុជា | ៣០៧៤ |
| ៣០-១១-២០០១ | - ព្រះរាជក្រឹត្យ នស/រកត/១១០១/៤៤៨ ស្ដីពីការតែងតាំងឯកឧត្ដម **ខា ឌុន** ជាទីប្រឹក្សាកិត្តិយសរបស់ឯកឧត្ដម **ញឹក ប៊ុនឆៃ** អនុប្រធានទី២ព្រឹទ្ធសភាទទួលបន្ទុកការងារសុខាភិបាលដោយពុំទទួលប្រាក់បៀវត្ស | ៣០៧៥ |


## II- រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


| | | |
|---|---|---|
| ២៧-១១-២០០១ | - អនុក្រឹត្យលេខ ៤៩០ អនក្រ.តត ស្ដីពីការជូនមេដាយការងារ | ៣០៧៦ |
| ២៩-១១-២០០១ | - អនុក្រឹត្យលេខ ៤៩១ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ | ៣០៧៨ |
| ២៩-១១-២០០១ | - អនុក្រឹត្យលេខ ៤៩២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៣០៧៩ |
| ២៩-១១-២០០១ | - អនុក្រឹត្យលេខ ៤៩៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៣០៨០ |
| ២៩-១១-២០០១ | - អនុក្រឹត្យលេខ ៤៩៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៣០៨១ |
| ៣០-១១-២០០១ | -Gouvernement Royal N° 495 OCM .IR | ៣០៨២ |
| ៣០-១១-២០០១ | - អនុក្រឹត្យលេខ ៤៩៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៣០៨៣ |
| ៣០-១១-២០០១ | - អនុក្រឹត្យលេខ ៤៩៧ អនក្រ.តត ស្ដីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ | ៣០៨៤ |
| ៣០-១១-២០០១ | - អនុក្រឹត្យលេខ ៤៩៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ | ៣០៨៥ |

៣០-១១-២០០១ - អនុក្រឹត្យលេខ ៨៩៩ អនក្រ.តត ស្ដីពីការតែងតាំងភារកិច្ចបន្ថែមជូនមន្ត្រីរាជការ ៣០៨៦

## ២. សេចក្ដីសំរេច

២៩-១១-២០០១ -សេចក្ដីសំរេចលេខ ៧០ សសរ ស្ដីពីការព្យួរការងារមន្ត្រីរាជការ ៣០៨៧

## III- ការងារបណ្ដាក្រសួង

### ១. ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៣-១១-២០០១ - ប្រកាសលេខ ៨៦៦ សហវ.ប្រក ស្ដីពីការអនុវត្តន៍អាករបន្ថែមលើពន្ធគយ នៃផលិតផលប្រេងកាត ៣០៨៩

២៨-១១-២០០១ - ប្រកាសលេខ ៨៨៧ សហវ.ប្រក លុបចោលនូវកាតព្វកិច្ចមូលនិធិទ្រទ្រង់សមរភូមិមុខ ៣០៩១

២៩-១១-២០០១ - សេចក្ដីជូនដំណឹងលេខ ០២៥ សហវ. ៣០៩៣

### ២. ទីស្ដីការរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

២៧-១១-២០០១ - សេចក្ដីសំរេចលេខ ០២១ សសរ.ដនស ស្ដីពីការបង្កើតភ្នាក់ងារប្រតិបត្តិគំរោងរៀបចំឯកសារអនុវត្តច្បាប់ភូមិបាលបណ្ដុះបណ្ដាល និង ផ្សព្វផ្សាយច្បាប់ភូមិបាល ៣០៩៤

### ៣. ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៦-១១-២០០១ - ប្រកាសលេខ ៧៤៤ ឧរថ.បល .ប្រក ស្ដីពីការបង្កើតក្រុមប្រឹក្សាវិន័យ ៣០៩៦

២៦-១១-២០០១ - ប្រកាសលេខ ៧៥២ ឧរថ.កឧ .ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ជេ.ឌីអាយ អ៊ិនធើណេសិនណល អ៊ិន (J-DI INTERNATIONAL INC )តំណាងដោយលោក WU SHUI –CHIH សញ្ជាតិចិន ( តៃវ៉ាន់ )បង្កើតរោងចក្រ " ផលិតកេសកាតុង " ដែលមានឈ្មោះថា " ជេ.ឌីអាយ អ៊ិនធើណេសិនណល អ៊ិន " មានទីតាំងស្ថិតនៅដីឡូតិ៍លេខ ១៣៧ ផ្លូវលេខ ១៩៨៦ សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ៣០៩៨

### ៤. ក្រសួងធនធានទឹក និង ឧតុនិយម

២៧-១១-២០០១ - សេចក្ដីសំរេចលេខ ៤១១ សសរ.ធទឧ ស្ដីពីការបង្កើតក្រុមការងារ លើគំរោងអភិវឌ្ឍន៍ វិស័យធារាសាស្ត្រនៅភូមិភាគពាយ័ព្យផ្នែក " ក " កសាងសមត្ថភាព ៣១០០

### ៥. ក្រសួងសង្គមកិច្ចការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

២៩-១១-២០០១ - ប្រកាសលេខ ៣១៥ សកបយ ស្ដីពីរបៀបគិតអតីតភាពការងារដើម្បីកំណត់ថិរវេលាដែលត្រូវឱ្យដំណឹងមុនសំរាប់កម្មករនិយោជិត ដែលមិនធ្វើការប្រចាំខែ ៣១០២

២៩-១១-២០០១ - ប្រកាសលេខ ៣១៦ សកបយ ស្ដីពី ការប្រើប្រាសកម្មករ និយោជិត ប្រភេទខ្លះខុសពីម៉ោងធ្វើការរួម ៣១០៤

២៩-១១-២០០១ -ប្រកាសលេខ ៣១៧ សកបយ ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម ៣១០៦

២៩-១១-២០០១ -ប្រកាសលេខ ៣១៨ សកបយ ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល ៣១០៩

**៦. ទីស្តីការរដ្ឋមន្ត្រី ក្រសួង ផែនការ**

២៧-១១-២០០១ -ប្រកាសលេខ ១៥៧ ប្រ-ផក ស្តីពីលទ្ធផលប្រឡងជ្រើសរើសចូលរៀននៅមជ្ឈមណ្ឌលបណ្តុះ បណ្តាលផែនការ-ស្ថិតិ ៣១១២

**៧. ទីស្តីការរដ្ឋមន្ត្រី ក្រសួង អប់រំ យុវជន និង កីឡា**

២៧-១១-២០០១ - ប្រកាសលេខ ៨៤៤ អយក-ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា "គោកត្រប់" មកជាសាលាបឋមសិក្សា "គោកត្រប់ ម៉ុនស្មែរ" ៣១១៨

**៨. ទីស្តីការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ**

៣០-១១-២០០១ - សារាចរលេខ ០០១ សរ ស្តីពីផែនការបង្ការ បង្ក្រាប និងទប់ស្កាត់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅតាមខេត្ត-ក្រុងនានា ៣១១៩

នស/រកត/១១០១/៤៤៣

# ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដាក់អោយចូលនិវត្តន៍ក្នុងក្របខ័ណ្ឌរដ្ឋបាលសាធារណៈ មន្ត្រីថ្នាក់ដឹកនាំនិងទីប្រឹក្សាក្រសួង និងឧត្តមប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រ ដូចមានរាយនាមខាងក្រោម :

| | |
|---|---|
| ១-ឯកឧត្តម ឃី តាំងលីម | រដ្ឋមន្ត្រី ក្រសួងសាធារណការនិងដឹកជញ្ជូន |
| ២-ឯកឧត្តម អ៊ុក ម៉ាន់ | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការនិងដឹកជញ្ជូន |
| ៣-ឯកឧត្តម មាសមេទន្ត កែមីវ៉ាន | ទីប្រឹក្សាអម ក្រសួងសាធារណការនិងដឹកជញ្ជូន |
| ៤-ឯកឧត្តម ឈរ អឿម | រដ្ឋលេខាធិការ ក្រសួងធម្មការនិងសាសនា |
| ៥-ឯកឧត្តម ជោគ ណារិន | អនុរដ្ឋលេខាធិការ ក្រសួងធម្មការនិងសាសនា |
| ៦-ឯកឧត្តម ឈឹម សៀវឡេង | ឧត្តមប្រឹក្សាផ្ទាល់ របស់ព្រះមហាក្សត្រ |

មាត្រា ២ : មន្ត្រីថ្នាក់ដឹកនាំនិងទីប្រឹក្សាអមក្រសួង និងឧត្តមប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រ ដែលត្រូវបានដាក់អោយចូលនិវត្តន៍ ដូចមានរាយនាមក្នុងមាត្រា ១ ខាងលើ នៅតែបន្តការងារក្នុងមុខតំណែងរបស់ខ្លួនដដែល រហូតដល់មានការសំរេចជាថ្មី ។

មាត្រា ៣ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខៈ ២៩២ ច.ល

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០១

៣៧ល-០១-១១-០០៣៩

បានឃើញថតចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០១

ទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការរាជរដ្ឋាភិបាល

[signature]

ព្រះ ណារ៉ាឌី ឡាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៤៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៧៨៨ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១

## ត្រាស់បង្គាប់

**មាត្រា១** .- តែងតាំងអ្នកម្នាង **ណារី ស៊ីសុវត្ថិ** ជាឧបករីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២** .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ៧៩៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាង ឆាន់**

ករស-០១.១១.០០៤០

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៤៥

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៧៩៦ សរ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១

## ត្រាស់បង្គាប់

**មាត្រា១ .-** តែងតាំងលោកជំទាវ **សាំង សូម៉ាលី** ជាទីប្រឹក្សាប្រធានរដ្ឋសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ៤៩៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិ ឆ្នាំ ២០០១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណារិន តាន់**

៣រល-០១-១១-០០៤១

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៤៦

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៨០៥ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០១

## ត្រាស់បង្គាប់

**មាត្រា១ .-** តែងតាំងឯកឧត្តម **វង្ស ជាវិន** ជាទីប្រឹក្សាប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុកពាក្យបណ្តឹងផ្សេងៗ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ៧៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឆាឌី សាន់**

ជ/ស-០១-១១-០០៤៧

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៤៧

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៨០២ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០១

## ត្រាស់បង្គាប់

**មាត្រា១ .-** តែងតាំងលោកជំទាវ **ឈឹម ណាឡា** ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ៤៩៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០១

៣/ល-០២.១១-០០៤៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៤៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២១ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា

ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ជា ជុន ជាទីប្រឹក្សាកិត្តិយសរបស់ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី២ព្រឹទ្ធសភា ទទួលបន្ទុកការងារសុខាភិបាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្សរ៍ ។

**មាត្រា ២ :** ប្រធានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ២៩៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ... ឆ្នាំ ២០...

អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០១

៣រល.០១.១១.០០៤៤

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូនវិស្វករចំនួន ០៩ រូប ដែលមានស្នាដៃក្នុងកម្មវិធីកែលំអផ្លូវលំជនបទ និង កម្មវិធីសង្គ្រោះបន្ទាន់ ( TRIP ) តាំងពីឆ្នាំ ១៩៩៥ រហូតមកដល់បច្ចុប្បន្ននេះ តាមរូបភាពសំរបសំរួល និង អនុវត្តការងារ ដូចមានរាយនាមខាងក្រោមនេះ ÷

**ក_មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១-លោក | **លូច** | **ឡូវ** | ប្រធានរដ្ឋបាលកម្មវិធីកែលំអផ្លូវលំជនបទ |
| ២-លោក | **ឯក** | **ណារុន** | វិស្វករកម្មវិធីកែលំអផ្លូវលំជនបទ |
| ៣-លោក | **លុយ** | **ណារិន** | វិស្វករកម្មវិធីកែលំអផ្លូវលំជនបទ |
| ៤-លោក | **សេង** | **ឈុនហេង** | វិស្វករកម្មវិធីកែលំអផ្លូវលំជនបទ |
| ៥-លោក | **គង់** | **តឿន** | វិស្វករកម្មវិធីកែលំអផ្លូវលំជនបទ |
| ៦-លោក | **យ៉ង់** | **ហាក់** | វិស្វករកម្មវិធីកែលំអផ្លូវលំជនបទ |
| ៧-លោក | **លឹម** | **ឡុង** | វិស្វករកម្មវិធីកែលំអផ្លូវលំជនបទ |

ខ-មេជាងត្រួតការងារ ៖

១-លោក ឈុន វ៉ុន វិស្វករកម្មវិធីសង្គ្រោះបន្ទាន់

២-លោក ជា ឡេង វិស្វករកម្មវិធីសង្គ្រោះបន្ទាន់

មាត្រា ២ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៩១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ. ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោកវេជ្ជបណ្ឌិត **គុំ កាណាល់** ជាប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកនៃក្រសួងសុខាភិបាល ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០១
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៩៧ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជប៉ុន ០៣ រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួនជួយកសាងអគារសិក្សា ០៣ ខ្នង មាន ១៦ បន្ទប់ ព្រមទាំងបំពាក់សំភារៈសិក្សាគ្រប់គ្រាន់ នៅសាលាបឋមសិក្សាបឹងទូក ឃុំបឹងទូក អនុវិទ្យាល័យត្រពាំងរពៅ ឃុំព្រែកត្នោត និង សាលាបឋមសិក្សាទ្វារថ្មី ឃុំព្រៃថ្នង ស្រុកកំពត ខេត្តកំពត ដូចមានរាយនាមខាងក្រោម ÷

១ - តំណាងសហជីពកម្មករ **ភូម៉ាស៊ូ** ថវិកា ៣០.០០០ USD

២ - លោក **យូស៊ីមី ហ្សាគូជី** ថវិកា ២៦.០០០ USD

៣ - លោក **គូបូតា** ថវិកា ២៦.០០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៤៩៣...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តបាត់ដំបង

## ស ម្រេ ច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ **CIAI** អ៊ីតាលី ដែលបានជួយកសាងអគារមន្ទីរពេទ្យ និងផ្ទះស្នាក់នៅ ក្នុងបូរីកុមារកំព្រា ខេត្តបាត់ដំបង ចំណាយអស់ទឹកប្រាក់សរុប ចំនួន ៥៥.៥០០ ដុល្លារអាមេរិក និងសំភារៈជាច្រើន ព្រមទាំងជួយរក ឪពុក ម្តាយធម៌ ឧបត្ថម្ភកុមារក្រីក្រ ក្នុងមួយខែៗ អស់ចំនួន ២.៩៧០.០០០រៀលថែមទៀត ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ /

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤៩៤...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តបាត់ដំបង

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក តូនី រូតធីម៉ាន់ TONI RUTTIMANN សប្បុរសជន ជនជាតិស្វីស ដែលបានលះបង់ខ្ពស់ទាំងកំលាំងកាយចិត្ត បញ្ញា ស្មារតី សំភារៈ និង ថវិកា សហការជាមួយប្រជារាស្ត្រ ក្នុងការសាងសង់ស្ពានយោល បានសំរេចចំនួន ០៨ កន្លែង នៅក្នុងខេត្តបាត់ដំបង ខេត្តសៀមរាប និង ក្រុងប៉ៃលិន ស្ពាននិមួយៗ មានតំលៃប្រមាណពី ៦.០០០ USD ទៅ ១០.០០០ USD ព្រមទាំងមានគំរោងសាងសង់ស្ពានចំនួន ០៣ កន្លែងទៀត ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ៕

រាជធានីភ្នំពេញ , ថ្ងៃទី[illegible]ខែ[illegible] ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

ព្រះរាជាណាចក្រកម្ពុជា
*Royaume du Cambodge*

រាជរដ្ឋាភិបាល
*Gouvernement Royal*

ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion Roi*

No.: 495 OCM. IR.

*Phnom Penh, le 30 Novembre, 2001*

**Monsieur Mike Moore**
**Directeur General**
**Organisation Mondiale du Commerce**
**Genève, Swisse**

Monsieur le Directeur Général,

J'ai l'honneur de vous informer que le Gouvernement Royal du Cambodge a nommé Monsieur Suos Someth, présent President d'Honneur du Conseil Suprême de l'Economie Nationale (Ministre d'Etat), en qualité d'Ambassadeur, Représentant permanent du Royaume du Cambodge auprès de l'Organisation Mondiale du Commerce à Genève.

En cette qualité, Son Excellence Monsieur Suos Someth possède tous les pouvoirs nécéssaires à l'exécution de sa fonction auprès de l'Organisation Mondiale du Commerce.

Je vous prie d'agréer, Monsieur le Directeur Général, les assurances de ma très haute considération.

Premier Ministre

HUN SEN

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៩៦ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## ស ំ រេ ច

**មាត្រា ១** :ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនចំពោះអ្នកឧកញ៉ា **គិត ម៉េង** ប្រធានក្រុមហ៊ុន **Royal Group** ដែលបានជួយឧបត្ថម្ភថវិកាចំនួន ២០ , ០០០ USD ដើម្បីជួយបំពេញបន្ថែមក្នុងការសាងសង់អគារសំរាប់ធ្វើជាមជ្ឈមណ្ឌល ចែកចាយប្រព័ន្ធទូរស័ព្ទ នៅក្នុងទីរួមខេត្តសៀមរាប ។

**មាត្រា ២** :រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ /នស /៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦ /១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ច លោក **ឡោ ស៊ើ** បច្ចុប្បន្នសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម មកជាអគ្គនាយករង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមាននាមចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ ៕/

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែវិច្ឆិកា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៤៩៥ អនក្រ.តត.

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- យោងតាមសំណើររបស់ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រី ០២ រូប នៃក្រសួងអប់រំ យុវជន និង កីឡា ។

១_លោក ម៉ុក ឆាន់ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានឧត្តមសិក្សាបច្ចេកទេស និង វិជ្ជាជីវៈ

២_លោក សំ សើរីតន៍ ជាប្រធាននាយកដ្ឋានផែនការ

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ_កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៨២២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងភារកិច្ចបន្ថែមជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តរបស់អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- យោងតាមសំណើរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងភារកិច្ចបន្ថែមជូនឯកឧត្តម **ធូ ថុន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ជាអគ្គលេខាធិការរងអចិន្ត្រៃយ៍ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :៤៤០ សសរ

# សេចក្តីសំរេច

## ស្តីពីការព្យួរការងារមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / រកម / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦៧ / អនក្រ / បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងមន្ត្រីរាជការ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល ។

## សំរេច

**ប្រការ ១** : ត្រូវបានព្យួរការងារមន្ត្រីរាជការពីររូប ដែលបានប្រព្រឹត្តខុសក្នុងជំពូកទី ០៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលតាមការកំណត់ដូចខាងក្រោម :

ក- លោក អ៊ុំ ទិចិត្រ បច្ចុប្បន្នជាប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងសុខាភិបាល ត្រូវព្យួរការងារអោយនៅទំនេរគ្មានបៀវត្សរយៈពេល ០៦ ខែ ដោយគិតចាប់តាំងពីថ្ងៃចុះហត្ថលេខា តទៅ និងផ្លាស់អោយទៅបំរើការងារនៅកន្លែងផ្សេង

ខ- លោក ជា គីមឡុង បច្ចុប្បន្នជាប្រធាននាយកដ្ឋានថវិកានិងហិរញ្ញវត្ថុ ត្រូវព្យួរការងារអោយនៅទំនេរគ្មានបៀវត្សរយៈពេល ០៣ ខែ ។

**ប្រការ ២ :** ក្នុងរយៈពេលព្យួរការងារ បើគណៈកម្មការស្រាវជ្រាវករណីមិនប្រក្រតីពិនិត្យឃើញថា សាមីខ្លួនទាំងពីរពុំមានបង្កបញ្ហាខុសឆ្គងតទៅទៀតទេនោះ ទីស្តីការគណៈរដ្ឋមន្ត្រី នឹងធ្វើលិខិតជូនទៅរាជរដ្ឋាភិបាល ដើម្បីស្នើសុំការអនុញ្ញាតតែងតាំងអោយមន្ត្រីទាំងពីរ បានចូលធ្វើការតាមការកំណត់ខាងលើ ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៨៣៣ សហវ.ប្រក.

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០១

## ប្រកាស
## ស្តីពី
## ការអនុវត្តន៍អាករបន្ថែមលើពន្ធគយ នៃផលិតផលប្រេងកាត

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នរ/រកម/០១.៩៩/០១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩
- បានឃើញ សារាចររបស់រាជរដ្ឋាភិបាលលេខ ០៦.សរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ១៩៩៩ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការកែទំរង់សេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០១ លើលិខិតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ៥៤១៨ សហវ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០១
- យោងតាមសំណូមពរការងារចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធអាករ

## សំរេច

**ប្រការ១ :** ត្រូវបានដាក់ឱ្យអនុវត្ត ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០២ តទៅ នូវអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតតាមអត្រាប្រាក់រៀលស្មើនឹង ពីរសេន ដុល្លារអាមេរិក សំរាប់ប្រេងសាំងប្រភេទE.A មួយលីត្រ និង បួនសេន ដុល្លារអាមេរិក សំរាប់ប្រេងម៉ាស៊ូត មួយលីត្រ ។

**ប្រការ ២** : អាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតនេះ ត្រូវបានគ្រប់គ្រង និងប្រមូលនៅតាមមាត់ច្រកនាំចូល ព្រះរាជាណាចក្រកម្ពុជា នាពេលនាំចូលដោយ ទីចាត់ការគយនិងរដ្ឋាករ ក្នុងលក្ខខណ្ឌ និងបទបញ្ញត្តិដូចគ្នានឹងការប្រមូលកំរៃយកមុន នៃផលិតផលប្រេងកាត ( RPP )។

**ប្រការ ៣** : ចំណូលដែលទីចាត់ការគយនិងរដ្ឋាករប្រមូលបានពីអាករបន្ថែម នៃពន្ធគយ លើផលិតផលប្រេងកាតនេះ ត្រូវកត់ត្រាចូលខ្ទង់ចំណូលតាមនាមវលីថវិកា លេខ ១៣.០១.០៥ស្តីពីអាករបន្ថែមនៃពន្ធគយ លើផលិតផលប្រេងកាត ។

**ប្រការ ៤** : ចំពោះទំនិញដូចមានចែងខាងលើនេះ ដែលបាននាំចូល និងបានធ្វើបែបបទនៃការមកដល់ មុនថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០២ ប៉ុន្តែមិនទាន់បានបំពេញបែបបទបង់ ឬ ប្រមូលពន្ធ អាករ និងកំរៃនានា នឹងពុំត្រូវបានអនុវត្តការប្រមូលអាករបន្ថែមនៃពន្ធគយ លើផលិតផលប្រេងកាតនេះឡើយ ។

**ប្រការ ៥** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦** : ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពន្ធដារ ប្រធានរតនាគារជាតិ ព្រមទាំងប្រធានអង្គភាពពាក់ពន្ធ័ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី ( ដើម្បីជូនជាពត៌មាន )
- សភាពាណិជ្ជកម្ម ( ដើម្បីសហការផ្សព្វផ្សាយនិងអនុវត្ត )
- ឯកសារ-កាលប្បវត្តិ

ឆ្នាំទី ៥ លេខ ៤៤ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០១ រាជកិច្ច ទំព័រ ៣០៩១

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៥៥៧ សហវ.ពដ.

រាជធានីភ្នំពេញ,ថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ២០០១

**ប្រកាស**

**ស្តីពី**

**ការលុបចោលនូវកាតព្វកិច្ចមូលនិធិទ្រទ្រង់សមរភូមិមុខ**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នរ/រកម/០១.៩៩/០១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩
- បានឃើញ សារាចរបស់រាជរដ្ឋាភិបាលលេខ ០៦.សរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ១៩៩៩ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការកែទំរង់សេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០០១ លើលិខិតលេខ ៥៧៥៣ សហវ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ប្រកាសលេខ ០៣០ កហវ.ប្រក. ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ១៩៩១ របស់ក្រសួងហិរញ្ញវត្ថុ ស្តីពីការបង្កើតមូលនិធិទ្រទ្រង់សមរភូមិមុខ
- យោងតាមសំណូមពរការងារចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធអាករ

**សំរេច**

ប្រការ ១ : ត្រូវបានលុបចោល ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០២ តទៅ នូវកាតព្វកិច្ចមូលនិធិទ្រទ្រង់សមរភូមិមុខដែលជាកំរៃយកមុនលើផលិតផលប្រេងកាត ។

**ប្រការ ២** : ចំពោះផលិតផលប្រេងកាតដែលជាប់កាតព្វកិច្ចមូលនិធិទ្រទ្រង់សមរភូមិមុខ ហើយបាននាំចូល និងបានធ្វើបែបបទនៃការមកដល់ មុនថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០២ ប៉ុន្តែមិនទាន់បានបំពេញបែបបទបង់ ឬ ប្រមូលពន្ធ អាករ និងកំរៃនានា ត្រូវអនុវត្តការប្រមូលមូលនិធិទ្រទ្រង់សមរភូមិមុខនេះដូចបែបបទចាស់ ។

**ប្រការ ៣** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤** : ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពន្ធដារ ប្រធានរតនាគារជាតិ ព្រមទាំងប្រធានអង្គភាពពាក់ពន្ធ័ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី ( ដើម្បីជូនជាព័ត៌មាន )
- សភាពាណិជ្ជកម្ម ( ដើម្បីសហការផ្សព្វផ្សាយនិងអនុវត្ត )
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០២៥ សហវ

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០០១

# សេចក្ដីជូនដំណឹង

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជំរាបជូនដំណឹងដល់លោកឧកញ៉ា លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលជាអគ្គនាយក បណ្ណាធិការ ឬ តំណាងបណ្ដាក្រុមហ៊ុន អាជីវកម្មនាំចូលសន្និធិ និងចរាចរ ចែកចាយផលិតផលប្រេងកាតក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា អនុលោមតាមខ្លឹមសារប្រកាសលេខ ៨៦៦ សហវ.ប្រក. ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០១ ស្ដីពីការអនុវត្តន៍អាករបន្ថែមលើពន្ធគយ នៃផលិតផលប្រេងកាត និងប្រកាសលេខ ៨៨៧ សហវ.ប្រក. ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០០១ ស្ដីពីការលុបចោលនូវកាតព្វកិច្ចមូលនិធិទ្រទ្រង់សមរភូមិមុខ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០២ នេះតទៅ មានការកែសម្រួលនូវកាតព្វកិច្ចពន្ធ អាករ និងកំរៃមួយចំនួនលើការនាំចូលផលិតផលប្រេងកាតដូចខាងក្រោម :

១- ដាក់ឱ្យអនុវត្តការប្រមូលអាករបន្ថែម នៃពន្ធគយលើផលិតផលប្រេងកាតតាមអត្រាប្រាក់រៀលស្មើនឹងពីរសេនដុល្លារអាមេរិក សំរាប់ប្រេងសាំងប្រភេទ E.A មួយលីត្រ និង បួនសេន ដុល្លារអាមេរិក សំរាប់ប្រេងម៉ាស៊ូត មួយលីត្រ នាពេលនាំចូល ។

២- លុបចោលកាតព្វកិច្ចបង់មូលនិធិទ្រទ្រង់សមរភូមិមុខដែលជាកំរៃយកមុនលើផលិតផលប្រេងកាត RPP ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមលោកឧកញ៉ា លោកជំទាវ អស់លោក លោកស្រីទាំងអស់ដូចមានរៀបរាប់ខាងលើជ្រាបជាពត៌មាននិងសូមចូលរួមសហការអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាពតាមការគួរ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់យ៉ាងមុតមាំនូវស្មារតីសហការល្អរបស់ លោកឧកញ៉ា លោកជំទាវ អស់លោក លោកស្រីទាំងអស់ ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច ក៏ដូចជាការកាត់បន្ថយភាពក្រីក្រនៅព្រះរាជាណាចក្រកម្ពុជា ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន :**

- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី ( ជូនជាពត៌មាន )
- ទីចាត់ការគយនិងរដ្ឋាករ
- សភាពាណិជ្ជកម្ម ( ដើម្បីជ្រាប និងសហការអនុវត្ត )
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
លេខ : ...០២១...ស.ស.រ/ជនស

ភ្នំពេញ ថ្ងៃទី...២៧...ខែ...វិច្ឆិកា...ឆ្នាំ២០០១

# សេចក្ដីសំរេច
## ស្ដីពី
## ការបង្កើតក្រុមការងារប្រតិបត្តិគំរោងរៀបចំឯកសារអនុវត្តច្បាប់ភូមិបាល បណ្ដុះបណ្ដាល និង ផ្សព្វផ្សាយច្បាប់ភូមិបាល

## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- តាមការចាំបាច់របស់ក្រសួង

## សំរេច :

**ប្រការ១ :** ត្រូវបានបង្កើតក្រុមការងារប្រតិបត្តិគំរោងរៀបចំឯកសារអនុវត្តច្បាប់ភូមិបាល បណ្ដុះបណ្ដាល និង ផ្សព្វផ្សាយច្បាប់ភូមិបាល ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | វង្ស សារីន | អនុរដ្ឋលេខាធិការ | ជាប្រធាន |
| ២-ឯកឧត្តម | ធូ ចុន | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល | ជាអនុប្រធាន |

៣-លោក លីម វ៉ាន់ អគ្គនាយករង នៃអគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ ជាសមាជិក

៤-លោក ជាម សុផល ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសមាជិក

៥-លោក សៀក វណ្ណា ប្រធាននាយកដ្ឋានគ្រប់គ្រងដីធ្លី ជាសមាជិក

៦- លោក សរ សាមេធា ប្រធាននាយកដ្ឋាននីតិកម្ម ជាសមាជិក

**ប្រការ២** : ភ្នាក់ងារប្រតិបត្តិគំរោងនេះមានភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ និង ពិនិត្យកែសំរួលសេចក្តីព្រាងច្បាប់បំពេញបន្ថែម ព្រះរាជក្រឹត្យ អនុក្រឹត្យ និង បទដ្ឋានផ្សេងៗ សំរាប់អនុវត្តច្បាប់ភូមិបាល
- សិក្សាស្រាវជ្រាវ និង ពិនិត្យជ្រើសរើសខ្លឹមសារ ដើម្បីរៀបចំ និង កសាងអត្ថបទបណ្តុះបណ្តាល និង ផ្សព្វផ្សាយច្បាប់ឱ្យឆ្លើយតបតាមមុខសញ្ញានីមួយៗ
- រៀបចំផែនការសកម្មភាពការងារ និង គំរោងអនុវត្ត
- រៀបចំបើកវគ្គបណ្តុះបណ្តាលច្បាប់ដល់មន្ត្រីរាជការ ក្រោមឱវាទក្រសួង និង មន្ត្រីនៃស្ថាប័នពាក់ព័ន្ធ
- រៀបចំការផ្សព្វផ្សាយច្បាប់តាមគ្រប់រូបភាពដល់សាធារណជន
- បោះពុម្ព និង ចែកផ្សាយឯកសារ
- ចុះធ្វើទំនាក់ទំនងការងារតាមខេត្ត-ក្រុង ដើម្បីរៀបចំការបណ្តុះបណ្តាល និង ផ្សព្វផ្សាយច្បាប់
- តាមដាន វាយតំលៃការអនុវត្តការងារ និង ធ្វើរបាយការណ៍ ។

**ប្រការ៣** : ភ្នាក់ងារប្រតិបត្តិគំរោងនេះត្រូវរៀបចំរបៀបរបបការងាររបស់ខ្លួន និងធ្វើរបាយការណ៍ជូនក្រសួងឱ្យបានទៀងទាត់ ។

**ប្រការ៤** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៥** : នាយកខុទ្ទកាល័យ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន ប្រធានគ្រប់នាយកដ្ឋាន និង ឯកឧត្តម អស់លោក អ្នកស្រី ដូចមាន ឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចម្លងជូន :

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-លេខាធិការដ្ឋានកម្មវិធី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
-គ្រប់ថ្នាក់ដឹកនាំក្រសួង ដ.ន.ស.
-ដូចក្នុងប្រការ១

អ៊ឹម ឈុនលឹម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion king

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry,Mines and Energy
N°៧៤៤ ឧរថ.បល.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមប្រឹក្សាវិន័យ

## រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់បង្កើតក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញ អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញកំណត់បង្ហាញលេខ ២២៣ អធ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០១ និងលេខ ២៤៨ អធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០១ របស់អគ្គាធិការដ្ឋាន
- បានឃើញកំណត់បង្ហាញ លេខ ៣១២ បល.កប ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០១ របស់នាយកដ្ឋានបុគ្គលិក
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១** : បង្កើតក្រុមប្រឹក្សាវិន័យរបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ដែលមានសមាសភាពដូចខាងក្រោម ដើម្បីធ្វើ

ការអង្កេតបាតុភាពខុសឆ្គងលើការងារដឹកនាំ គ្រប់គ្រង របស់លោក ខុង ខឹមសាវ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត កោះកុង :

១-ឯកឧត្តម ញ៉ឹក ឡើង អនុរដ្ឋលេខាធិការ ប្រធាន

២-លោក ឈឹម នួន ប្រធាននាយកដ្ឋានបុគ្គលិក សមាជិក

៣-លោក ចើរ ចេន្ធា ប្រធានការិយាល័យរដ្ឋបាលកិច្ចការកិច្ចហិរញ្ញវត្ថុ លេខាធិការ

៤-លោក ចយឿ សារឿ អនុប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកោះកុង សមាជិក

៥-លោក កែវ សុវណ្ណរ៉ាន ប្រធានអង្គភាពរដ្ឋបាលទឹកនៃមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត កោះកុង សមាជិក

**ប្រការ២ :** រាល់លទ្ធផលការងារដែលទទួលបានពីការធ្វើអង្កេតនេះ ក្រុមប្រឹក្សាវិន័យត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរ ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសំរេច ។

**ប្រការ៣ :** អគ្គាធិការ នៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ និងឯកឧត្តម អស់លោកដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

**ប្រការ៤ :** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ន.៦៨៧

ភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០០១

ស៊ុយ សែម

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកោះកុង

-ដូចប្រការ៣ " ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion king

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry,Mines and Energy
№ ៧៥៤ ឧរថក.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០០១

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ន.ស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ. បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតលេខ ២៨៤៦/០១ គ.វ.ក ចុះថ្ងៃទី ១២.០៩.២០០១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- បានឃើញប្រកាសលេខ ២២៣ ប.ស្តប្រ.ក វហបស្ត ចុះថ្ងៃទី ២៤.១០.២០០១ របស់ក្រសួងបរិស្ថាន ។
- បានឃើញលិខិតលេខ ៤៣១ លអ.ស ចុះថ្ងៃទី ០៩.០៨.២០០១ របស់សាលាក្រុងភ្នំពេញ ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ជេ. ឌីអាយ អ៊ិនធើណេសិនណល អ៊ីន ចុះថ្ងៃទី២៦.១០.២០០១។

## សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ជេ. ឌីអាយ អ៊ិនធើណេសិនណល អ៊ីន (J-DI INTERNATIONAL INC.) តំណាងដោយលោក WU SHUI-CHIH សញ្ជាតិចិន (តៃវ៉ាន់) អាយុ៥៤ ឆ្នាំ ភេទប្រុស កាន់លិខិតឆ្លងដែនលេខ M16848930 ចុះថ្ងៃទី 02.10.99 បង្កើតរោងចក្រ "ផលិតកេសកាតុង" ដែលមានឈ្មោះថា "ជេ.ឌីអាយ អ៊ិនធើណេសិនណល អ៊ីន" មានទីតាំងស្ថិតនៅដីឡូត៍លេខ ១៣៧ ផ្លូវលេខ១៩៨៦ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។/.

<u>ប្រការ២</u> : ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានសំរេចក្នុងរយៈពេល ១២ខែ ដោយរាប់បញ្ចូលទាំងរយៈពេលសាកល្បងផង ។

<u>ប្រការ៣</u> : រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ " ផលិតកេសកាតុង " ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៤</u> : ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀតនៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

<u>ប្រការ៥</u> : ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៦</u> : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៧</u> : ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

<u>ប្រការ៨</u> : ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវអស់សុពលភាព ។

<u>ប្រការ៩</u> : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុនជេ. ឌីអាយ អ៊ិនធើណេសិនណល អ៊ីន ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀង១ខ្លួន ។

<u>ប្រការ១០</u> : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ Kee

ស៊ុយ សែម

<u>ចម្លងជូន</u>

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -រាជកិច្ច
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- -ក្រសួងសង្គមកិច្ច-ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- -ក្រសួងបរិស្ថាន
- -ក្រសួងពាណិជ្ជកម្ម
- -សាលាក្រុងភ្នំពេញ

" <u>ដើម្បីជូនជ្រាបជាពត៌មាន</u> "

- -<u>ដូចប្រការ ៩ " ដើម្បីអនុវត្ត</u>
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងធនធានទឹក និង ឧតុនិយម**

លេខ ///// ស្រប.ធទឧ.

# សេចក្តីសំរេច

## ស្តីពីការបង្កើតក្រុមការងារលើគំរោងអភិវឌ្ឍន៍ វិស័យធារាសាស្ត្រនៅភូមិភាគពាយ័ព្យផ្នែក "គ" កសាងសមត្ថភាព

&&&&&&&&

## រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញលិខិតលេខ A-001 ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០១ របស់ជំនាញការផ្នែកកសាងសមត្ថភាព
- បានពិនិត្យសំណូមពរចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០០១ របស់ឯកឧត្តម អគ្គនាយកកិច្ចការរដ្ឋបាល និងជានាយកគំរោងកសាងសមត្ថភាព
- បានឃើញការចាំបាច់របស់ក្រសួងធនធានទឹក និងឧតុនិយម

## សំរេច

**ប្រការ ១ :**

បង្កើតក្រុមការងាររបស់ក្រសួងសំរាប់សហការជាមួយក្រុមជំនាញការបច្ចេកទេសដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តម **លី ចាន់ណា** | អគ្គនាយកកិច្ចការរដ្ឋបាល | នាយកគំរោង |
| ២. លោក **ពេជ្រ ចាន់សេនា** | ប្រធាននា. ផែនការ និងសហប្រតិបត្តិការអន្តរជាតិ | អ្នកចាត់ចែងគំរោង |
| ៣. លោក **ថេង តារា** | ប្រធាននាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក | សមភាគី |
| ៤. លោក **ខៅ ឈុនគៀត** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស | សមភាគី |
| ៥. លោក **ឌឹត មុំសោ** | អនុប្រធានការិយាល័យសហប្រតិបត្តិការអន្តរជាតិ | សមភាគី |
| ៦. លោក **កែ វិចិត** | មន្ត្រីនាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ | សមភាគី |

**ប្រការ ២ :**

ក្រុមការងារខាងលើនេះ មានភារកិច្ចសហការការងារជាមួយទីប្រឹក្សាបច្ចេកទេសនៃគំរោងអភិវឌ្ឍន៍ វិស័យធារាសាស្ត្រនៅភូមិភាគពាយ័ព្យផ្នែក "ក" កសាងសមត្ថភាព North West Irrigation Sector Project, "Part A" Capacity Building ( TA No 3758-CAM ) ។

**ប្រការ ៣ :**

អគ្គនាយកក្រសួង ប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក និងឯកឧត្តម អស់លោកដូចមានក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ខែ វិច្ឆិកា ឆ្នាំ ២០០១

**រដ្ឋមន្ត្រី**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
- ដូចក្នុងប្រការ ៣ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ៣១៤ សកបយ.

ភ្នំពេញ. ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ២០០១

# ប្រកាស
## ស្តីពី
## របៀបគិតអតីតភាពការងារ ដើម្បីកំណត់ថិរវេលាដែលត្រូវអោយដំណឹងមុនសំរាប់កម្មករនិយោជិត ដែលមិនធ្វើការប្រចាំខែ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** អតីតភាពការងារដើម្បីយកមកកំណត់ថិរវេលា ដែលត្រូវអោយដំណឹងមុននៅពេលធ្វើការបញ្ឈប់កម្មករនិយោជិត ដែលបានចុះកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ និងដែលមិនធ្វើការប្រចាំខែ ត្រូវគិតស្មើនឹងរយៈពេល ដែលកម្មករនិយោជិតនោះជាប់កិច្ចសន្យាជាមួយនិយោជក ទោះបីការអនុវត្តន៍កិច្ចសន្យានោះត្រូវបានព្យួរ ឬកាត់ផ្តាច់ម្តងម្កាលក៏ដោយ ពោលគឺអតីតភាពការងារនេះត្រូវគិតចាប់ពីថ្ងៃចូលធ្វើការដំបូងរហូតដល់ថ្ងៃបញ្ឈប់ពីការងារ។

ប្រការ២.- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ២០៧ សករ. ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៣.- ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**<u>ចម្លងជូន</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_____

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ០១២៨ សកបយ.

ភ្នំពេញ ថ្ងៃទី២៨ ខែ[illegible] ឆ្នាំ២០០១

## ប្រកាស
## ស្តីពី
## ការប្រើប្រាស់កម្មករនិយោជិតប្រភេទខ្លះខុសពីម៉ោងធ្វើការរួម

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## ស ំ រេ ច

**ប្រការ១.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានមានសិទ្ធិប្រើប្រាស់កម្មករនិយោជិតរបស់ខ្លួន ខុសពីម៉ោងធ្វើការដែលបានកំណត់ជារួម ។ កម្មករនិយោជិតប្រភេទនេះមានជាអាទិ៍:-

-អ្នកទទួលខុសត្រូវថែទាំគ្រឿងម៉ាស៊ីន និងថាមពលភ្លើង

-អ្នកទទួលខុសត្រូវបោសសំអាត បំរើភ្ញៀវ បើកបរ និងជួសជុលទីកន្លែងធ្វើការ

-អ្នកទទួលខុសត្រូវយាមកាមសហគ្រាស គ្រឹះស្ថាន។

**ប្រការ២.**- ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវបើកតារាងបញ្ជីឈ្មោះ និងម៉ោងធ្វើការដោយឡែករបស់កម្មករនិយោជិតប្រភេទដូចមានចែងក្នុងប្រការ១ ខាងលើ ដែលត្រូវរក្សាទុកជាប្រចាំសំរាប់ការត្រួតពិនិត្យជាទៀង-ទាត់របស់អធិការការងារ ។

**ប្រការ៣.**- កម្មករនិយោជិតប្រភេទដូចមានចែងក្នុងប្រការ១ ខាងលើមានសិទ្ធិ នឹងអនុវត្តដូចកម្មករនិយោជិតដទៃទៀតអំពីថិរវេលាធ្វើការ ការចែកពេលធ្វើការប្រចាំថ្ងៃ ប្រាក់ឈ្នួលពេលធ្វើការបន្ថែមម៉ោង និងការទូទាត់ម៉ោងធ្វើការដែលខកខានមិនបានធ្វើ ។

**ប្រការ៤.**- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ៩២ សកអ.ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥.**- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**<u>ចម្លងជូន</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

  "ដើម្បីជ្រាប"

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- កាលប្បវត្តិ និងឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ៣១៧ សកបយ.

ភ្នំពេញ ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ២០០១

## ប្រកាស
## ស្តីពី
## នីតិវិធីនៃការដោះស្រាយវិវាទការងាររួម

### រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

### សំរេច

**ប្រការ១.-** ចំពោះការដោះស្រាយវិវាទការងាររួម បើក្នុងអនុសញ្ញារួមមិនបានគ្រោងនីតិវិធីសំរាប់ការដោះស្រាយទេ គ្រប់រឿងវិវាទត្រូវតែភាគីណាមួយប្តឹងទៅអធិការកិច្ចការងារ ។

នាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិ - សម្បទា ស្ថិតនៅអាគារលេខ ២៨ វិថីសម្តេចព្រះធម្មលិខិតអ៊ុក " ផ្លូវលេខ ១៨៤ " សង្កាត់ជ័យជំនះ ខណ្ឌ

ជូនពេញ មានសមត្ថកិច្ចទទួលខុសត្រូវដោះស្រាយវិវាទការងាររួម ដែលកើតមាននៅរាជធានីភ្នំពេញ ។

មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុងដទៃទៀត មានសមត្ថកិច្ចទទួលខុសត្រូវដោះស្រាយវិវាទការងាររួម ដែលកើតមាននៅខេត្ត-ក្រុងរៀង១ខ្លួន ។

**ប្រការ២.** ក្រោយពីបានទទួលបណ្តឹងរបស់ភាគីណាមួយ អធិការការងារត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់តាំងអ្នកផ្សះផ្សាម្នាក់ក្នុងរយៈពេល៤៨ ម៉ោង ។ បន្ទាប់មកអ្នកផ្សះផ្សាត្រូវធ្វើលិខិតអញ្ជើញទៅភាគីទាំងអស់មកផ្តល់នូវពតិមាន និងឯកសារជាភស្តុតាងនានា ដើម្បីផ្សះផ្សាវិវាទអោយបានសមស្រប ។

ការសាកសួរពតិមានបន្ថែម ត្រូវធ្វើឡើងមួយភាគីម្តង១ ដាច់ដោយឡែកពីគ្នា ។ គ្រប់ពេលសាកសួរពតិមានបន្ថែមត្រូវធ្វើកំណត់ហេតុទុកជាឯកសារ ដោយមានចុះហត្ថលេខាអ្នកផ្សះផ្សា និងភាគីដែលផ្តល់ពតិ-មាននោះផង ។

ភាគីទាំងពីរត្រូវតែចូលរួមប្រជុំតាមការអញ្ជើញរបស់អ្នកផ្សះផ្សា ។

បើភាគីណាមួយមិនចូលរួមប្រជុំទេនោះ អ្នកផ្សះផ្សាត្រូវរាយការណ៍ ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់វិធានការទៅតាមច្បាប់ស្តីពីការងារ ។

**ប្រការ៣.** ក្នុងករណីដែលបានទទួលពតិមានសព្វគ្រប់ពីភាគីទាំងអស់ហើយ អ្នកផ្សះផ្សាត្រូវធ្វើលិខិតអញ្ជើញម្តងទៀតអោយភាគីដែលពាក់ព័ន្ធទាំងអស់មកចូលរួមប្រជុំជាមួយគ្នា ដើម្បីធ្វើការផ្សះផ្សា ។

ការផ្សះផ្សាត្រូវធ្វើក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីពេលបានទទួលសេចក្តីបង្គាប់ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។ ការផ្សះផ្សានេះអាចធ្វើឡើងវិញបានតែតាមសំណូមពររួមនៃភាគីវិវាទ ។

ភាគីទាំងពីរត្រូវតែចូលរួមប្រជុំតាមការអញ្ជើញរបស់អ្នកផ្សះផ្សា ។ បើភាគីណាមួយមិនចូលរួមប្រជុំទេនោះ អ្នកផ្សះផ្សាត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិ-សម្បទា ដើម្បីចាត់វិធានការទៅតាមច្បាប់ស្តីពីការងារ ។

**ប្រការ៤.** លិខិតអញ្ជើញដែលមានចែងក្នុងប្រការ២ និងប្រការ៣ ខាងលើ ត្រូវផ្ញើជូនភាគីវិវាទតាមសំបុត្រអនុសិដ្ឋដែលមានហត្ថលេខាបញ្ជាក់ថាបានទទួលហើយ ឬលិខិតជូនផ្ទាល់ដៃដោយមានចុះហត្ថលេខាថាបានទទួល ។

**ប្រការ៥.** ភាគីវិវាទអាចអោយគេជួយអម ឬអោយគេតំណាងខ្លួនបាន ។ ជនទាំងឡាយដែលអាចជួយអម ឬធ្វើជាតំណាងរបស់ភាគីវិវាទបាន លុះត្រាតែជនទាំងនោះជាមនុស្សពេញវ័យដែលច្បាប់ទទួលស្គាល់ ហើយអាចសំរេចកិច្ចការបានផង ។

**ប្រការ៦.** ត្រូវធ្វើកំណត់ហេតុនៅរាល់ពេលប្រជុំផ្សះផ្សា ដោយមានបញ្ជាក់ច្បាស់លាស់ពីការយល់ព្រម ឬមិនយល់

ព្រមព្រៀងសះជានោះ ។ ករណីពុំមានហេតុផលនេះត្រូវបិទផ្សាយការដោយអ្នកផ្សះផ្សាព្រមទាំងហេតុផលការរបស់ភាគីដែលពុំព្រម និងត្រូវចម្លងផ្ញើភាគីទាំងពីរ ។

**ប្រការ៧.-** ការព្រមព្រៀងសះជាដែលបានចុះហត្ថលេខាដោយភាគី និងបានចុះទិដ្ឋាការដោយអ្នកផ្សះផ្សា មានតម្លៃ និងអនុភាពដូចគ្នា និងអនុសញ្ញារួមរវាងភាគី និងរវាងអ្នកដែលអោយគេតំណាងខ្លួន ។ ប៉ុន្តែប្រសិនបើភាគីតំណាងកម្មករនិយោជិតពុំមែនជាអង្គការសហជីពវិជ្ជាជីវៈណាមួយទេ ការព្រមព្រៀងនេះមិនជំទាស់ទាំងចំ-ពោះអង្គការសហជីពនោះ ទាំងចំពោះកម្មករនិយោជិតដែលអោយគេតំណាងខ្លួន ។

**ប្រការ៨.-** ចំពោះវិវាទការងាររួមដែលភាគីពុំបានប្ដឹង ឬអោយដំណឹងមកអធិការកិច្ចការងារទេនោះ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អាចចាត់ការផ្សះផ្សាតាមនីតិវិធីដែលកំណត់ក្នុងប្រការ២ ប្រការ៣ ប្រការ៤ ប្រការ៥ និងប្រការ៦ ខាងលើ ក្រោយពីបានដំណឹងពីវិវាទនេះភ្លាម ។

**ប្រការ៩.-** វិវាទការងាររួមណាដែលមានការប៉ះពាល់ ឬអាចបណ្ដាលអោយប៉ះពាល់ដល់សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈអធិការកិច្ចការងារ ក្រោយពីបានទទួលដំណឹងស្ដីពីវិវាទនេះ ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ជូនរដ្ឋ-មន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់តាំងអ្នកផ្សះផ្សា និងចាត់ការធ្វើការផ្សះផ្សាភ្លាមៗ ចុះសាកសួរពត៌មាន និងធ្វើការផ្សះផ្សាដល់ទីកន្លែងតែម្ដង ។

**ប្រការ១០.-** បើមានអនុសញ្ញាបានគ្រោងពីនីតិវិធីច្បាស់លាស់ សំរាប់ដោះស្រាយវិវាទការងាររួមហើយនោះ វិវាទការងាររួមត្រូវតែដោះស្រាយតាមនីតិវិធីនៃអនុសញ្ញានេះ ។

**ប្រការ១១.-** ចំពោះវិវាទការងាររួមដែលផ្សះផ្សាមិនព្រមសះជា អ្នកផ្សះផ្សាត្រូវរាយការណ៍ជាបន្ទាន់ ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីមានវិធានការដោះស្រាយបន្ត ។

**ប្រការ១២.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៨៦២ សកអ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ១៩៩៦ និង លេខ ១៤៤ សកអ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៣.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"

-អគ្គនាយកដ្ឋាន ការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សអ

MOSALVY

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា

លេខ ៣១៨ សកបយ

ភ្នំពេញ ថ្ងៃទី២៦ ខែ១១ ឆ្នាំ២០០១

ប្រកាស

ស្តីពី

នីតិវិធីនៃការដោះស្រាយវិវាទបុគ្គល

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

សម្រេច

**ប្រការ១.-** ក្នុងការដោះស្រាយវិវាទបុគ្គល មុននឹងប្តឹងទៅតុលាការ ភាគីណាមួយអាចប្តឹងជាលាយលក្ខណ៍អក្សរទៅអធិការការងារ ដើម្បីធ្វើការផ្សះផ្សាជាមុនសិន។

នាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្ថិតនៅអាគារលេខ ២៨ ផ្លូវសម្តេចព្រះធម្មលិខិតអ៊ុក" ផ្លូវលេខ១៨៤" សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ មានសមត្ថកិច្ចទទួលខុសត្រូវផ្សះផ្សាវិវាទការងារនៅរាជធានីភ្នំពេញ។

មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុងដទៃទៀត មានសមត្ថ

[illegible]។

**ប្រការ២.-** [illegible]

[illegible] ដើម្បីស្វែងរក[illegible]វិវាទ[illegible]។

ការសាកសួរពត៌មានបន្ថែមនេះ ត្រូវធ្វើឡើងរួមរវាងភាគីម្ខាងដាច់ដោយឡែកពីគ្នា ។ គ្រប់ពេលសាកសួរពត៌មានបន្ថែម ត្រូវធ្វើកំណត់ហេតុទុកជាឯកសារដោយមានចុះហត្ថលេខាអធិការការងារ និងភាគីដែលផ្តល់ពត៌មាននោះផង ។ កំណត់ហេតុនេះត្រូវផ្តល់ជូនភាគីដែលផ្តល់ពត៌មាន ១ ច្បាប់ផង ។

**ប្រការ៣.-** បើភាគីដើមចោទ ឬតំណាងនៃជននេះ មិនព្រមអញ្ជើញទៅផ្តល់ពត៌មានបន្ថែមជូនអធិការការងារតាមកាលកំណត់ ឬក្នុងរយះពេលបីថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកំណត់ " គិតតែថ្ងៃធ្វើការ " ដោយគ្មានមូលហេតុសមស្របទេនោះ ពាក្យប្តឹងនោះត្រូវទុកជាមោឃៈ ។

បើភាគីចុងចោទ ឬតំណាងនៃជននេះ មិនព្រមចូលបង្ហាញខ្លួនតាមកាលកំណត់ ឬក្នុងរយះពេលបីថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកំណត់ " គិតតែថ្ងៃធ្វើការ " ដោយគ្មានមូលហេតុសមស្របទេនោះ រឿងវិវាទត្រូវចាត់ទុកថាមិនសះជា ហើយត្រូវចាត់ទុកថា ភាគីចុងចោទមានកំហុសដូចការចោទប្រកាន់របស់ភាគីដើមចោទទាំងស្រុង ។

**ប្រការ៤.-** បន្ទាប់ពីបានទទួលពត៌មានសព្វគ្រប់អស់ហើយ អធិការការងារត្រូវធ្វើលិខិតអញ្ជើញម្តងទៀតអោយភាគីទាំងសងខាងចូលរួមប្រជុំជាមួយគ្នាដើម្បីធ្វើការផ្សះផ្សា ។

អធិការការងារត្រូវធ្វើការផ្សះផ្សាវិវាទបុគ្គលក្នុងរយះពេលបីសប្តាហ៍យ៉ាងយូរបន្ទាប់ពីបានទទួលពាក្យប្តឹង ។

ភាគីវិវាទអាចអោយគេជួយអម ឬអោយគេតំណាងខ្លួនបាន ។

បើភាគីដើមចោទ ឬតំណាងនៃជននេះមិនចូលរួមប្រជុំតាមការកំណត់ ហើយគ្មានបញ្ជាក់មូលហេតុសមស្របទេនោះ ពាក្យប្តឹងត្រូវចាត់ទុកជាមោឃៈ ។

បើភាគីចុងចោទ ឬតំណាងនៃជននេះ មិនចូលរួមប្រជុំតាមការកំណត់ ហើយគ្មានបញ្ជាក់មូលហេតុសមស្របទេនោះ រឿងវិវាទត្រូវចាត់ទុកថាមិនសះជា ហើយត្រូវចាត់ទុកថាភាគីចុងចោទមានកំហុសដូចការចោទប្រកាន់របស់ភាគីដើមចោទទាំងស្រុង ។

**ប្រការ៥.-** លិខិតអញ្ជើញដែលមានចែងក្នុងប្រការ២ និងប្រការ៤ ខាងលើ ត្រូវផ្ញើជូនភាគីតាមសំបុត្រអនុសិដ្ឋ ឬលិខិតជូនផ្ទាល់ដៃ ដែលមានចុះហត្ថលេខាបញ្ជាក់ថាបានទទួលហើយ ។

**ប្រការ៦.-** ជនទាំងឡាយនឹងអាចជួយអម ឬធ្វើជាតំណាងរបស់ភាគីវិវាទបានលុះត្រាតែជននោះជាមនុស្សពេញវ័យដែលច្បាប់ទទួលស្គាល់ ហើយអាចសំរេចកិច្ចការបានផង ។

**ប្រការ៧.-** ត្រូវធ្វើកំណត់ហេតុនៅរាល់ពេលប្រជុំផ្សះផ្សាដោយមានបញ្ជាក់ច្បាស់លាស់ពីការយល់ព្រម ឬមិនយល់

ព្រមសះជាមិនបាន ។ ក្នុងករណីនេះ ត្រូវធ្វើកំណត់ហេតុដោយអធិការការងារ ព្រមទាំងហត្ថលេខារបស់ភាគី ទាំងសងខាង និងត្រូវចម្លងប្រគល់ជូនភាគីនីមួយៗ ។

**ប្រការ៨.-** ការព្រមព្រៀងដែលបានធ្វើនៅចំពោះមុខអធិការការងារ គឺជាការព្រមព្រៀងយកជាការបានចំពោះមុខច្បាប់ ។

**ប្រការ៩.-** ក្នុងករណីមិនសះជា ដោយរាប់ទាំងការមិនសះជាដែលមានកំណត់ក្នុងប្រការ៣ និងប្រការ៤ ខាងលើផង អធិការការងារត្រូវជំរាបទៅភាគី អំពីសិទ្ធិរបស់ភាគីដើមចោទដែលអាចធ្វើពាក្យប្តឹងជាបន្តទៅតុលាការមានសមត្ថកិច្ច ទៅតាមបែបបទដែលមានកំណត់ក្នុងច្បាប់ ។

**ប្រការ១០.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ២២ សកអ. ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ១៩៩៤ និងលេខ ១៤៥ សកអ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១១.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

***************

ក្រសួងផែនការ

លេខ:...157៦...ផក

# ប្រកាស

ភ្នំពេញ, ថ្ងៃទី 27 ខែ 11 ឆ្នាំ ២០០1

ស្ដីពី

## លទ្ធផលប្រឡងជ្រើសរើសចូលរៀន

## នៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលផែនការ_ស្ថិតិ

*******

## រដ្ឋមន្ត្រីក្រសួងផែនការ

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២ នស/១៩៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រិត្យលេខ២០អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានឃើញ ព្រះរាជក្រមលេខនស/រកម/០១៩៦/១១ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងផែនការ

-បានឃើញអនុក្រិត្យលេខ ៥៥អនក្រ/បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ផែនការ

-បានឃើញ ប្រកាសលេខ ១៤៤ ប្រ.ផក ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ២០០១ ស្ដីពីការចាត់តាំងគណៈកម្មការប្រឡងជ្រើសរើសមន្ត្រីរាជការ និង សិស្ស អោយចូលរៀននៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលផែនការ-ស្ថិតិ ។

-បានឃើញសេចក្ដីជូនដំណឹងលេខ ២២២២ អយក.អបរ ចុះថ្ងៃទី ០៧ ខែសីហាឆ្នាំ ២០០១ ស្ដីពីការប្រឡងជ្រើសរើសសិស្សចូលរៀនក្នុងគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស និង បណ្ដុះបណ្ដាលវិជ្ជាជីវៈរបស់ក្រសួងអប់រំយុវជននិងកីឡា ។

-យោងស្មារតីអង្គប្រជុំរបស់គណៈកម្មការប្រឡងអនុម័តលទ្ធផលនៃការប្រឡងជ្រើសរើសថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០១

## សំរេច

**ប្រការ១**:-បេក្ខជនទាំងពីរភេទដែលមានរាយនាមក្នុងតារាងឧបសម្ព័ន្ធត្រូវបានទទួលស្គាល់ថាបានប្រឡងជាប់ជាស្ថាពរ ។

**ប្រការ២**:-បេក្ខជនទាំងអស់ដែលមានរាយនាមក្នុងបញ្ជីតារាងឧបសម្ព័ន្ធ ត្រូវបានអនុញ្ញាតអោយចូលរៀននៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលផែនការ-ស្ថិតិ ។

**ប្រការ៣**:-អង្គភាពក្រោមឱវាទក្រសួងផែនការ មជ្ឈមណ្ឌលបណ្ដុះបណ្ដាលផែនការ-ស្ថិតិ មានភារកិច្ចអនុវត្តតាម សេចក្ដី ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ឆាយ_ថន

**ចម្លងជូន**

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងអប់រំយុវជនកីឡា

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ឯកសារ

-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងផែនការ**
**មជ្ឈមណ្ឌលបណ្តុះបណ្តាល ផែនការ-ស្ថិតិ**

## បញ្ជីរាយនាមលទ្ធផលប្រឡងជ្រើសរើសសិស្សជំនាន់ទី ១៤ ចូលរៀននៅមជ្ឈមណ្ឌលបណ្តុះបណ្តាល ផែនការ-ស្ថិតិ ឆ្នាំសិក្សា ២០០១-២០០២

(យោងប្រកាសលេខ 157 ប្រក.ផក ចុះថ្ងៃទី 27 ខែ 11 ឆ្នាំ ២០០១)

| ល.រ | នាមនិងគោត្តនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | មកពី | លេខបន្ទប់ | លេខតុ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| 1 | កែវ គឹមសួ | ស | ១១/០៨/១៩៨៤ | វិ.សម្តេចឪ | 1 | 15 | |
| 2 | ប៉ែន ចន្ទី | ស | ១៥/០៣/១៩៨៤ | វិ.ឥន្ទ្រទេវី | 7 | 174 | |
| 3 | ជ្រុន ថៅវង្ស | ប | ១៨/០៤/១៩៨៣ | វិ.ទួលទំពូង | 3 | 69 | |
| 4 | ជា ស៊ីវត្រា | ប | ១៧/០៥/១៩៨៤ | វិ.ឫស្សីកែវ | 4 | 83 | |
| 5 | ផល លក្ខិណា | ស | ០១/០៨/១៩៨៤ | វិ.បាក់ទូក | 7 | 180 | |
| 6 | ផល ពៅរចនា | ស | ០៣/០១/១៩៨៣ | វិ.បាក់ទូក | 7 | 183 | |
| 7 | កុំ សារ៉ុម | ប | ១៥/០៦/១៩៨៤ | វិ.សម្តេចជាស៊ីមអង្គរជ័យ | 8 | 191 | |
| 8 | កូ បូរ៉ាម៉ែត | ស | ១៦/០១/១៩៨២ | វិ.ហ៊ុនសែនវត្តស្វាយ | 8 | 192 | |
| 9 | អ៊ុំ ស៊ីនួន | ស | ១៩/០៥/១៩៨៣ | វិ.ព្រះស៊ីសុវត្ថិ | 15 | 393 | |
| 10 | អ៊ិល សុភ័ហេ | ស | ២០/១០/១៩៨៣ | វិ.ឥន្ទ្រទេវី | 15 | 399 | |
| 11 | អាន សារ៉េត | ប | ១៥/០៨/១៩៨០ | វិ.ព្រះយុគន្ធរ | 15 | 405 | |
| 12 | ចាយ ដាឡែន | ស | ១៥/០៨/១៩៨៤ | វិ.មុនីវង្ស | 2 | 49 | |
| 13 | ប៊ូច ចន្ទ្រាវុធ | ប | ១៨/០១/១៩៨២ | វិ.ភូមាស | 7 | 168 | |
| 14 | ផាន សុផារី | ស | ១២/០៥/១៩៨២ | វិ.សម្តេចម៉ែ | 7 | 182 | |
| 15 | លាង វីរៈ | ប | ២៤/០៦/១៩៨៣ | វិ.អនុវត្ត | 10 | 246 | |
| 16 | សួរ ប៊ុនម៉ារីយ៉ា | ស | ០១/១០/១៩៨៣ | វិ.ឥន្ទ្រទេវី | 11 | 295 | |
| 17 | សៅ សោមារង្សី | ប | ១៧/០៩/១៩៨២ | វិ.សន្ធរម៉ុក | 12 | 319 | |
| 18 | សេង រតនា | ប | ១២/០១/១៩៨៤ | វិ.ហ៊ុនសែនជម្ពូវ័ន | 13 | 329 | |
| 19 | សាយ សុភក្តិ | ប | ២១/០៣/១៩៨២ | វិ.សម្តេចជាស៊ីមអង្គរជ័យ | 13 | 334 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 20 | ហង់ ជឿន | ប | ១០/០៣/១៩៨០ | វិ.ព្រះស៊ីសុវត្ថិ | 13 | 345 | |
| 21 | ហែម បញ្ញើ | ប | ១៤/១១/១៩៨៣ | វិ.សន្ធរម៉ុក | 14 | 362 | |
| 22 | ភួន សុខា | ប | ២៥/០៦/១៩៨២ | វិ.ចំបក់ | 15 | 382 | |
| 23 | អោន និមល | ប | ១៥/១០/១៩៨៤ | វិ.ពាមរក៏ | 15 | 392 | |
| 24 | ខៀវ និន្ទ | ប | ១០/០៣/១៩៧៩ | វិ.ហ៊ុនសែនតាខ្មៅ | 1 | 18 | |
| 25 | ងន ភា | ប | ១៣/០៨/១៩៨៣ | វិ.ហ៊ុនសែនកោះធំ | 2 | 46 | |
| 26 | ជាវ ឡាលីន | ស | ០១/០១/១៩៨១ | វិ.សន្ធរម៉ុក | 4 | 94 | |
| 27 | ឈិន សុគន្ធ | ស | ០៥/០២/១៩៨២ | វិ.ជាស៊ីមតាកែវ | 4 | 102 | |
| 28 | ប៊ុក សុភា | ប | ០៥/០១/១៩៨២ | វិ.ហ៊ុនសែនតាខ្មៅ | 7 | 169 | |
| 29 | ប៉ាំង ផាន់ណារ៉ា | ប | ០២/០១/១៩៨៣ | វិ.ហ៊ុនសែនកោះធំ | 7 | 176 | |
| 30 | ភឿន រដ្ឋា | ប | ០២/១២/១៩៨១ | វិ.ញឹមវណ្ណដាពារាំង | 8 | 193 | |
| 31 | មាស វត្ថនា | ស | ១៥/០៥/១៩៨៣ | វិ.នេតយ៉ង | 8 | 202 | |
| 32 | យឹម ច័ន្ទបូរ | ប | ១៥/០៣/១៩៨៣ | វិ.សន្ធរម៉ុក | 9 | 228 | |
| 33 | រស់ សំភ័ស្ស | ប | ០៣/០៣/១៩៨៣ | វិ.ច្បារអំពៅ | 9 | 232 | |
| 34 | វ៉ាត នារីរតនា | ស | ២២/១០/១៩៨២ | វិ.សន្ធរម៉ុក | 10 | 259 | |
| 35 | ហ៊ុយ វុទ្ធី | ប | ១៧/១២/១៩៨៣ | វិ.ស្រុកភ្នំពេញ | 13 | 350 | |
| 36 | ឡាន សាវឿម | ប | ០៤/០៦/១៩៧៩ | វិ.កំពង់ធំ | 14 | 373 | |
| 37 | អេង គីមលី | ប | ២៦/០៧/១៩៨២ | វិ.ន.រណឫទ្ធិគន្ធបុប្ផា | 15 | 403 | |
| 38 | ម៉ៅ ពិសិដ្ឋ | ប | ០៧/០៨/១៩៨២ | វិ.ច្បារអំពៅ | 8 | 200 | |
| 39 | កែវ សុងសុសផ្សា | ស | ១០/១១/១៩៨១ | វិ. ព្រះយុគន្ធរ | 1 | 2 | |
| 40 | កែវ ធារី | ប | ០៣/០៥/១៩៧១ | វិ.ចតុមុខ | 1 | 3 | |
| 41 | ខេង មករា | ប | ១៣/០១/១៩៨៣ | វិ.១ឧសភា ខេត្តតាកែវ | 1 | 20 | |
| 42 | ឈឹម ធុល | ប | ២៥/០៩/១៩៧៩ | វិ.ព្រះបាទសុរាម្រឹត | 4 | 104 | |
| 43 | ឌឹម ស៊ាងណួន | ប | ១៥/០៨/១៩៨២ | វិ.ត្បូងឃ្មុំ | 5 | 113 | |
| 44 | តាំង ស្រីនីន | ស | ១០/០៩/១៩៨៣ | វិ.បាក់ទូក | 5 | 135 | |
| 45 | កុំ វណ្ណៈ | ប | ០៣/០៣/១៩៨២ | ក្រុងព្រះសីហនុ | 7 | 190 | |
| 46 | ម៉ូះ បូរ៉ាត | ប | ០៥/០១/១៩៨២ | វិ.ស្រុកភ្នំពេញ | 8 | 196 | |
| 47 | យ៉ុន ពិសាល | ប | ២៨/០៧/១៩៨១ | វិ.ទួលទំពូង | 9 | 225 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 48 | រ័ត្ន ស៊ីណោត | ប | ០១/០១/១៩៧៩ | មន្ត្រីផែនការខេត្តកណ្តាល | 9 | 231 | |
| 49 | រស់ គន្ធៈពៅវឌ្ឍនៈ | ប | ១១/០១/១៩៨៣ | វិ.ព្រះស៊ីសុវត្ថិ | 9 | 235 | |
| 50 | លឹម ភិរុណ | ប | ១៤/០២/១៩៨៤ | វិ.ជាស៊ីមកំពង់ថ្ម | 9 | 241 | |
| 51 | លី គីមស៊ាង | ប | ០៤/០៤/១៩៨៣ | វិ.ហ៊ុនសែនកោះធំ | 10 | 248 | |
| 52 | វេង លាក | ប | ១២/១០/១៩៧០ | វិ.សាយធូ | 10 | 266 | |
| 53 | សម្បត្តិ គុណា | ប | ១៥/១០/១៩៧៥ | វិ.ទួលទំពូង | 11 | 286 | |
| 54 | សាន់ តារី | ប | ១០/០២/១៩៨០ | វិ.សន្ធរម៉ុក | 12 | 301 | |
| 55 | ស៊ិន ហាន | ប | ០៤/០៧/១៩៨២ | វិ.ព្រះមុនីវង្ស | 12 | 303 | |
| 56 | សាន រចនា | ស | ១៦/០៣/១៩៨២ | វិ.ត្បូងឃ្មុំ | 12 | 310 | |
| 57 | សៀង សុភាព | ប | ០២/០៦/១៩៨២ | វិ.១ឧសភា | 13 | 339 | |
| 58 | ហែម សោភ័ណ្ឌ | ស | ០៧/១០/១៩៧៨ | វិ.ច្បារអំពៅ | 13 | 343 | |
| 59 | អ៊ិត សូឌីឡា | ប | ១០/១០/១៩៨៣ | វិ.សន្ធរម៉ុក | 15 | 383 | |
| 60 | អ៊ុម វីរៈ | ប | ១៤/០៨/១៩៨៣ | វិ.ជាស៊ីមកំពង់ថ្ម | 15 | 389 | |
| 61 | ចូ ហោម្សេន | ប | ១០/០៩/១៩៨៣ | វិ.ឫស្សីកែវ | 6 | 149 | |
| 62 | មន្ត ច័ន្ទសារេះ | ប | ០៩/០៩/១៩៨៥ | វិ.ឥន្ទ្រទេវី | 8 | 205 | |
| 63 | ចាន់ សារ៉ាក់ | ប | ០១/០៣/១៩៨០ | វិ.សន្ធរម៉ុក | 3 | 56 | |
| 64 | ណែត រុន | ប | ០១/០៣/១៩៨០ | វិ.មោងឫស្សី | 5 | 122 | |
| 65 | គ្រស់ សុភីរាប | ប | ១៥/០៣/១៩៧៨ | វិ.ព្រះមហាក្សត្រិយានីកុសុម | 5 | 125 | |
| 66 | ពៃ កែវនាង | ប | ១៩/០៣/១៩៨២ | វិ.ទួលទំពូង | 5 | 126 | |
| 67 | ពេញ ច័ន្ទរាសនា | ស | ១៣/០២/១៩៨៣ | វិ.បាក់ទូក | 7 | 188 | |
| 68 | សេក មករា | ប | ២៩/០១/១៩៨០ | វិ.ព្រះស៊ីសុវត្ថិ | 11 | 282 | |
| 69 | សេង សុវណ្ណាង | ប | ១០/០៧/១៩៨០ | វិ.ព្រះមហាក្សត្រីយានីកុសុមៈ | 11 | 296 | |
| 70 | សុភាព សីហា | ប | ០១/០៨/១៩៨១ | វិ.ហ៊ុនសែនកោះធំ | 12 | 305 | |
| 71 | សេង ឌីណាត | ប | ០៩/០១/១៩៨២ | វិ.ញ៉ូមវណ្ណដាពារាំង | 12 | 306 | |
| 72 | ស៊ីង សូលីណា | ស | ០៧/០៨/១៩៨៤ | វិ.វត្តកោះ | 12 | 307 | |
| 73 | សាយ ពលរក្សា | ប | ២៣/០៦/១៩៨៣ | វិ.បឹងត្របែក | 12 | 314 | |
| 74 | សាយ ទិត្យពិសិដ្ឋ | ប | ០៩/០៩/១៩៨២ | វិ.ព្រះស៊ីសុវត្ថិ | 12 | 315 | |
| 75 | ហាស់ ដាណោ | ស | ២៤/០៣/១៩៨១ | វិ.បឹងត្របែក | 13 | 340 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 76 | ហ៊ុន លីហេង | ប | ០៨/០១/១៩៧៤ | វិ.ទួលទំពូង | 13 | 349 | |
| 77 | ហូត ផល្លា | ប | ៣១/០៧/១៩៨១ | វិ.ឥន្រ្ទទេវី | 13 | 352 | |
| 78 | អ៊ឹង តុលា | ប | ១៥/១០/១៩៨៣ | វិ.ហ៊ុនសែនតាខ្មៅ | 15 | 384 | |
| 79 | ឆ័យ ម៉ូលីវណ្ណ | ប | ២១/០៤/១៩៨៣ | វិ.ឥន្រ្ទទេវី | 3 | 59 | |
| 80 | ឆាយ រតនា | ប | ២៣/១២/១៩៨២ | វិ.ទួលទំពូង | 3 | 63 | |
| 81 | ជឹម តុលា | ប | ០៧/១០/១៩៨២ | វិ.សន្ធរម៉ុក | 3 | 78 | |
| 82 | ជិន សុភា | ប | ១០/០២/១៩៨០ | វិ.ស្រុកភ្នំពេញ | 3 | 81 | |
| 83 | នេត ធីតា | ស | ១១/១១/១៩៨០ | វិ.បាក់ទូក | 6 | 158 | |
| 84 | លុយ សុភារុធ | ប | ១៥/១១/១៩៨០ | ខេត្តតាកែវ | 10 | 253 | |
| 85 | ស៊ុន ណារិន | ប | ០២/០៣/១៩៨៣ | វិ.មង្គលបូរី | 11 | 274 | |
| 86 | សេក វឌ្ឍនា | ប | ២០/០១/១៩៨៤ | វិ.ព្រះស៊ីសុវត្ថិ | 11 | 298 | |
| 87 | សេង សូរិយា | ប | ១២/០១/១៩៨៤ | វិ.ពោធិ៍សាត់ | 13 | 333 | |
| 88 | ហ៊ុយ វិបុល | ប | ៣០/០១/១៩៨៣ | វិ.បាក់ទូក | 13 | 344 | |
| 89 | ញាណ មករា | ប | ០៧/០១/១៩៨២ | វិ.សន្ធរម៉ុក | 5 | 109 | |
| 90 | ទុច ធីសុភ័ណ | ប | ២៥/១០/១៩៨១ | វិ.ភូមាស | 6 | 146 | |
| 91 | ទី សេងថៃ | ប | ២៧/០២/១៩៨០ | វិ.ហ៊ុនសែនកោះធំ | 6 | 148 | |
| 92 | ប៊ុន បូរត្ន័ | ប | ១០/១០/១៩៨១ | វិ.ហ៊ុនសែនតាគោក | 6 | 162 | |
| 93 | ជូ សូរិយា | ប | ២៩/១១/១៩៨១ | វិ.ស្រុកភ្នំពេញ | 4 | 90 | |
| 94 | នន់ ណាគ | ប | ១៥/០៧/១៩៨០ | វិ.សន្ធរម៉ុក | 6 | 160 | |
| 95 | ម៉ាក ចំរើន | ប | ១៤/០២/១៩៨២ | វិ.សម្តេចជាស៊ីមអង្គរជ័យ | 8 | 197 | |
| 96 | លាង សៀកឡាំង | ស | ២៧/០៩/១៩៨៤ | វិ.ហ៊ុនសែនកោះធំ | 10 | 254 | |
| 97 | ជា វុទ្ធថា | ប | ០២/០៨/១៩៨២ | វិ.ទួលទំពូង | 3 | 70 | |
| 98 | ណាវ មករា | ស | ០៥/០២/១៩៨៤ | វិ.ហ៊ុនសែនកោះធំ | 5 | 115 | |
| 99 | នង សុគន្ធារី | ស | ០៤/០៥/១៩៨៣ | វិ.ទន្លាប់ | 6 | 155 | |
| 100 | នួន ទី | ប | ០៦/០២/១៩៨២ | វិ.បាក់ទូក | 6 | 159 | |
| 101 | បូ ទី | ប | ១០/០២/១៩៨១ | វិ.ព្រះស៊ីសុវត្ថិ | 7 | 166 | |
| 102 | ម៉េង ហុងសេង | ស | ០១/០១/១៩៨១ | វិ.ជីហែ | 8 | 213 | |
| 103 | ព្រៃ ច័ន្ទភក្តី | ប | ២៧/១១/១៩៨៣ | ភ្នំពេញ | 7 | 187 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 104 | សរ សុគន្ធ | ស | ១៧/០៩/១៩៨២ | វិ.ព្រះយុគន្ធរ | 11 | 287 | |
| 105 | តូច សុក្ខា | ប | ០៧/០២/១៩៨០ | វិ.ទួលទំពូង | 5 | 129 | |
| 106 | ហុង គីមហ៊ុន | ប | ២៥/០៦/១៩៨៣ | វិ.សន្ធរម៉ុក | 14 | 367 | |
| 107 | ទេព ពិដោរ | ប | ១៩/០៤/១៩៨០ | វិ.ព្រះយុគន្ធរ | 6 | 142 | |
| 108 | ប៊ុន ណារ៉ា | ប | ៣០/១២/១៩៨១ | វិ.ទួលទំពូង | 7 | 173 | |
| 109 | ញ៉ាន់ ម៉ូនី | ប | ១០/១០/១៩៨២ | វិ.កំពង់កន្ទួត | 5 | 110 | |
| 110 | ឈាន សុវិទ្យា | ប | ១២/១២/១៩៨៣ | វិ.ព្រះស៊ីសុវត្ថិ | 4 | 100 | |
| 111 | អ៊ុំ ដេត | ប | ១០/០៩/១៩៦៨ | មន្ត្រីក្រសួងផែនការ | 15 | 388 | |
| 112 | នុត ស្រីទូច | ស | ១៥/១២/១៩៧១ | មន្ត្រីក្រសួងផែនការ | 6 | 161 | |
| 113 | អ៊ុក មរកត | ស | ០៣/០៨/១៩៧២ | មន្ត្រីក្រសួងផែនការ | 15 | 409 | |
| 114 | ជន ផល្លី | ស | ០៤/១១/១៩៧៣ | មន្ត្រីក្រសួងផែនការ | 4 | 97 | |
| 115 | ចាន់ ផាន់នី | ស | ២២/០២/១៩៧៣ | មន្ត្រីក្រសួងផែនការ | 2 | 54 | |
| 116 | នេត សុភី | ស | ១០/០៥/១៩៧៣ | មន្ត្រីក្រសួងផែនការ | 6 | 150 | |
| 117 | រស់ ប៊ុនដារ៉េណេ | ស | ០២/០៥/១៩៧១ | មន្ត្រីក្រសួងផែនការ | 9 | 234 | |
| 118 | ខៀវ ម៉ាដារី | ស | ១០/០៥/១៩៦៤ | មន្ត្រីក្រសួងផែនការ | 1 | 19 | |
| 119 | វ៉ាន់ ខន | ប | ១០/០១/១៩៥៩ | មន្ត្រីក្រសួងផែនការ | 10 | 262 | |
| 120 | ស៊ីសុវត្ថិ សត្យា | ស | ០១/០៩/១៩៧០ | មន្ត្រីក្រសួងផែនការ | 13 | 326 | |

រាជធានីភ្នំពេញ.ថ្ងៃទី 27 ខែ 11 ឆ្នាំ ២០០១

គណៈកម្មការប្រឡងជ្រើសរើស

ប្រធាន

[illegible]

លេខៈ 158....ផក

បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ.ថ្ងៃទី 27 ខែ 11 ឆ្នាំ ២០០១

រដ្ឋមន្ត្រី

ឆាយ_ថន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚ ❖ ៛

ក្រសួងអប់រំ យុវជន និង កីឡា

លេខ : 844 អយក-ប្រក

# ប្រកាស

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា " គោកត្រប់ "

មកជាសាលាបឋមសិក្សា " គោកត្រប់ ម៉ុនស្នែរ "

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ០៧៩៦-៩២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញព្រះរាជក្រឹត្យ លេខ ជស-រកត ០៨៩៧-១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ .ប.ក ចុះថ្ងៃទី ២៣ - ៣ - ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-បានពិនិត្យលិខិតរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សាគោកត្រប់ ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១ ដោយចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡាខេត្ត កណ្តាល ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០១ ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

**ប្រការ១** :- ប្តូរឈ្មោះសាលាបឋមសិក្សា គោកត្រប់ ដែលមានទីតាំងស្ថិតនៅឃុំ គោកត្រប់ ស្រុក កណ្តាលស្ទឹង ខេត្ត កណ្តាល មកជាសាលាបឋមសិក្សា " គោកត្រប់ ម៉ុន ស្នែរ " វិញចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣** :- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានហិរញ្ញវត្ថុ យកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជន និង កីឡា កណ្តាល ប្រធានការិយាល័យអប់រំយុវជន និង កីឡា ស្រុកកណ្តាលស្ទឹង ខេត្ត កណ្តាល នាយកសាលាបឋមសិក្សា "គោកត្រប់ម៉ុន ស្នែរ " មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី 27 ខែ 11 ឆ្នាំ២០០១

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

ទ្រឹម_សិទ្ធិ

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ " ដើម្បីជូនជ្រាបជាពត៌មាន "
- សាលាខេត្ត កណ្តាល " ជូនជ្រាបជាពត៌មាន "
- ដូចប្រការ ៣
- កាលប្បវត្តិ- ឯកសារ នា -ប.ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ ៖ ០០១ ស.ន

ភ្នំពេញ ថ្ងៃទី ៣០ ខែ ១១ ឆ្នាំ២០០១

## សារាចរ
## ស្តីពីផែនការបង្ការ បង្ក្រាប និងទប់ស្កាត់ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ នៅតាមខេត្ត ក្រុងនានា

※※※※※

សភាពការណ៍បទល្មើសគ្រឿងញៀន កំពុងបន្តកើតមាន និងកាន់តែមានកំរិតកើនឡើងគួរឱ្យព្រួយបារម្ភ នៅតាមទីប្រជុំជនខេត្ត ក្រុង និងបណ្តាស្រុកមួយចំនួនជាប់តំបន់ព្រំដែន ។ សកម្មភាពជួញដូរ និងប្រើប្រាស់គ្រឿងញៀនជាមុខព្រួញដ៏សំខាន់មួយ ដែលរាជរដ្ឋាភិបាលកំពុងខិតខំយកចិត្តទុកដាក់ដោះស្រាយ ។

ដើម្បីធានាបង្ការ បង្ក្រាប និងទប់ស្កាត់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ នៅតាមខេត្ត ក្រុងទូទាំងប្រទេស ក្រសួងមហាផ្ទៃដាក់ចេញសារាចរដើម្បីណែនាំអនុវត្តន៍ផែនការបង្ការបង្ក្រាប និងទប់ស្កាត់ដូចខាងក្រោម :

១-ជំរុញអនុវត្តន៍វិធានការជំនាញឱ្យបានខ្លាំងក្លា និងព្រមៗគ្នានៅទូទាំងប្រទេស ។ វិធានការជំនាញត្រូវអនុវត្តន៍ជាជំហានៗ ដោយត្រូវយកចិត្តទុកដាក់ :

-តម្លើងបញ្ជីមាតិការសមាសភាពជាមុខសញ្ញាក្នុងនោះរួមមាន ប្រភេទមេក្លោង សមាសភាពពាក់ព័ន្ធខ្សែនាំចូលគ្រឿងញៀនឆ្លងដែន មុខសញ្ញាផលិតគ្រឿងញៀន មុខសញ្ញាចែកចាយ ម្ចាស់អាជីវកម្ម សេវាកម្មស្របច្បាប់ តែប្រើប្រាស់គ្រឿងញៀនដើម្បីទាក់ទាញភ្ញៀវ ប្រភេទក្មេង ញៀនការហើត អ្នកចាក់ផឹកគ្រឿងញៀន (គិតទាំងជនបរទេសផង) ។

-បន្ទាប់ពីការតម្លើងបញ្ជីមុខសញ្ញាទាំងនោះរួចហើយ ត្រូវអនុវត្តន៍វិធានការគ្រប់គ្រងឱ្យបានម៉ត់ចត់ ប្រមែប្រមូលពត៌មានចងក្រងប្រមូលវត្ថុតាង ដើម្បីឈានទៅបើកករណីពស៊ើបបង្ក្រាបតាមនិតិវិធីច្បាប់ ។

២-ក្រោយការតម្លើងបញ្ជីមាតិការរួចហើយ ត្រូវធ្វើការបែងចែកប្រភេទ និងអនុវត្តន៍វិធានការដូចខាងក្រោម :

ក-មុខសញ្ញាមេក្លោង សមាសភាពពាក់ព័ន្ធ ឧក្រិដ្ឋជនគ្រឿងញៀនឆ្លងដែន មុខសញ្ញាផលិតគ្រឿងញៀន មុខសញ្ញាចែកចាយ ត្រូវជំរុញការប្រមែប្រមូលព័ត៌មាន វត្ថុតាង ដើម្បីឈានទៅបង្ក្រាបចាប់ផ្តន្ទាទោសតាមច្បាប់ ។

ខ-មុខសញ្ញាចាក់ដក់ ក្មេងញៀនការហិត ត្រូវប្រមូលផ្តុំ ដើម្បីធ្វើការអប់រំ ព្យាបាលតាមកំរិតលទ្ធភាពជាក់ស្តែងដែលយើងមាន ។ អាជ្ញាធរខេត្ត ក្រុង ត្រូវម្ចាស់ការទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយឧបត្ថម្ភក្នុងការបង្កើតមជ្ឈមណ្ឌលអប់រំ ព្យាបាល និងឈានទៅអប់រំនិតិសម្បទា ។

គ-គោលដៅអាជីវកម្មទាំងឡាយ ដែលសង្ស័យថាមានការចែកចាយ ឬប្រើប្រាស់គ្រឿងញៀន ដើម្បីទាក់ទាញភ្ញៀវ ត្រូវកោះអញ្ជើញធ្វើការអប់រំ និងចុះកិច្ចសន្យាមិនឱ្យមានការចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀននៅទីនោះ ។ ទន្ទឹមនោះត្រូវធ្វើការតាមដានជាប់ជាប្រចាំនៅតាមគោលដៅអាជីវកម្មទាំងនោះ ។

៣-ធ្វើសេចក្តីណែនាំ ជូនអាជ្ញាធរដែនដី ដើម្បីជូនដំណឹងដល់គ្រប់គោលដៅអាជីវកម្មទាំងអស់ ជាពិសេសភោជនីយដ្ឋាន ក្លឹបកំសាន្ត ក្លឹបខារ៉ាអូខេ ម៉ាស្សា រង្គសាល សណ្ឋាគារ ដោយបិទបំរាមហាមឃាត់មិនឱ្យមានការចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀន ដោយឱ្យម្ចាស់គោលដៅទាំងនោះចុះកិច្ចសន្យាជាមួយអាជ្ញាធរមានសមត្ថកិច្ច (ការជូនដំណឹងខាងលើត្រូវធ្វើជាប្រកាសរបស់សាលាខេត្ត ក្រុង) ។

-គោលដៅអាជីវកម្មណាដែលធ្វើល្មើសនឹងសេចក្តីប្រកាស ត្រូវអនុវត្តន៍ទណ្ឌកម្មតាមរូបភាពព្រមាន ឬបិទការធ្វើអាជីវកម្មជាបណ្តោះអាសន្នដោយមានកំណត់រយៈពេល ឬ បិទការធ្វើអាជីវកម្មដោយគ្មានកំណត់ពេល ឬ បិទជាស្ថាពរ ឬ ត្រូវចោទប្តឹងទៅតុលាការវិនិច្ឆ័យទោសតាមច្បាប់ ។

៤-សហការជាមួយស្ថាប័នពាក់ព័ន្ធ មានវិធានការគ្រប់គ្រងឱ្យបានម៉ត់ចត់បណ្តាក្រុមហ៊ុន ដែលសុំច្បាប់នាំចូលសារធាតុគីមី ដែលជាវត្ថុធាតុដើមអាចយកមកកែច្នៃផលិតគ្រឿងញៀនសំយោគបាន ។ ត្រូវធ្វើការប៉ាន់ប្រមាណធៀបផលិតផលសំរេចទៅនឹងសារធាតុគីមីដែលជាវត្ថុធាតុដើម ជៀសវាងការនាំចូលលើសសេចក្តីត្រូវការ នៃការផលិត ។

-ពេលដែលសារធាតុគីមីទាំងនោះធ្វើការនាំចូលមកហើយ ត្រូវបន្តធ្វើការគ្រប់គ្រងធ្វើយ៉ាងណាឱ្យសារធាតុគីមីទាំងនោះយកទៅប្រើប្រាស់ចំតាមគោលដៅ ។

៥-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវសហការជាមួយអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយប្រព័ន្ធឃោសនា និងជាមួយអង្គការមិនមែនរដ្ឋាភិបាល បង្កើនការអប់រំក្នុងជួរប្រជាពលរដ្ឋ សិស្សានុសិស្ស មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ឱ្យយល់ដឹងពីគ្រោះមហន្តរាយបណ្តាលមកពីគ្រឿងញៀន និងចូលរួមយ៉ាងសស្រាក់សស្រាំក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ ការប្រើប្រាស់គ្រឿង

ញៀន [illegible]

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ_______

៦-ដើម្បីចាត់តាំងឱ្យមានប្រសិទ្ធភាពសារាចរខាងលើនោះ ក្រសួងមហាផ្ទៃកំណត់ឱ្យខេត្ត ក្រុងនីមួយៗ បង្កើតគណៈកម្មការចំរុះមួយ ដឹកនាំដោយឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងឯកឧត្តមអភិបាលខេត្ត ដើម្បីជំរុញដឹកនាំតាមស្មារតីសារាចរនេះ ។

ចំពោះមុខប្រគល់ជូនឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុករាជធានីភ្នំពេញ ចាត់តាំងដឹកនាំអនុវត្តន៍ស្មារតីសារាចរនេះមុនគេរយៈពេល ០៣ខែ ដើម្បីដកបទពិសោធន៍ បន្ទាប់មកនឹងធ្វើការចាត់តាំងផ្សព្វផ្សាយបទពិសោធន៍នេះ ជូនដល់ ខេត្ត ក្រុងទូទាំងប្រទេស ដើម្បីចាត់តាំងអនុវត្តន៍ឱ្យបានព្រមគ្នា ។

ទទួលបានសារាចរនេះ អគ្គនាយកនគរបាលជាតិ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ឯកឧត្តមអភិបាលខេត្ត ក្រុង ត្រូវធ្វើការផ្សព្វផ្សាយជ្រួតជ្រាបដល់មន្ត្រីទទួលបន្ទុកអនុវត្តន៍ផ្ទាល់ ដើម្បីចាត់តាំងអនុវត្តន៍ឱ្យមានប្រសិទ្ធភាព ។

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង យូ ហុកគ្រី

ចម្លងជូន
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
-ក្រសួងការពារជាតិ
-ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងសង្គមកិច្ច យុវនីតិសម្បទា
"ដើម្បីជូនជ្រាប"
-អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
-ទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
"ដើម្បីសហការអនុវត្តន៍"
-អគ្គនាយកដ្ឋាននគរបាលជាតិ
-គ្រប់សាលា ខេត្ត ក្រុង
-គ្រប់ស្នងការដ្ឋាននគរបាលខេត្ត ក្រុង
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ